**ប្រការ ៤** : លោក NIELS STORM MARTENS - COLOV ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងមានត្រូវអនុវត្តន៍នូវប្រកាសនេះ ។

**ប្រការ ៥** : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

* * *

## ៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ១១៣ អយក.ប្រក**

**ស្តីពីផ្លាស់សាលាឧបសម្ព័ន្ធគរុកោសល្យ**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤

- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០-១១-១៩៨៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ តុលា ១៩៨៦ ស្ដីពីការកំនត់បទដ្ឋានប្រើ ប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំ របស់មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ លេខ ៥៩៨ លស. ចទម. ចុះថ្ងៃទី ១៥ ធ្នូ ១៩៩៥
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

**សម្រេច**

**ប្រការ ១ :** អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ ផ្តាច់សាលាភូមិឫស្សីឱុបសម្ព័ន្ធ សាលាបឋមសិក្សា ស្ទឹងមានជ័យ មកជា សាលាបឋមសិក្សាភូមិឫស្សីពេញលក្ខណៈ ចាប់ពី ឆ្នាំ ១៩៩៦ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សាភូមិឫស្សី ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក និងនាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋាន ផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និង កីឡា ខ័ណ្ឌមានជ័យ នាយកសាលាបឋមសិក្សា

ស្ទឹងមានជ័យ នាយកសាលាបឋមសិក្សាភូមិឫស្សី មានភារៈកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**គា សាហាន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ១១៤ អយក.ប្រក**

**ស្តីពីប្តូរឈ្មោះសាលាបឋមសិក្សា ចត្តុមុខ**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ តុលា ១៩៨៦ ស្តីពីការកំនត់បទដ្ឋានប្រើ ប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា ⁄